ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 16-Mar-2015, 16:00
CMS/CFO: Sann Rada

**អង្គជំនុំជម្រះតុលាការកំពូល**
Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខ: ០០២/១៩-កញ្ញា-២០០៧-អ.វ.ត.ក/អ.ជ.ត.ក
Case File/Dossier N°. 002/19-09-2007-ECCC/SC

| | |
|---|---|
| **នៅចំពោះមុខ៖** | **ចៅក្រម គង់ ស្រីម ជាប្រធាន** |
| | **ចៅក្រម Chandra Nihal JAYASINGHE** |
| | **ចៅក្រម សោម សិរីវឌ្ឍ** |
| | **ចៅក្រម Agnieszka KLONOWIECKA-MILART** |
| | **ចៅក្រម មុំ មុន្នីចរិយា** |
| | **ចៅក្រម Florence Ndepele MWACHANDE-MUMBA** |
| | **ចៅក្រម យ៉ា ណារិន** |
| **កាលបរិច្ឆេទ៖** | **ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៥** |
| **ភាសា៖** | **ខ្មែរ/អង់គ្លេស** |
| **ចំណាត់ថ្នាក់ឯកសារ៖** | **សាធារណៈ** |

---

# សេចក្តីសម្រេចលើផ្នែកខ្លះនៃសំណើលើកទីបីរបស់ នួន ជា សុំទទួលយក និងពិចារណាភស្តុតាងបន្ថែមក្នុងកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១

---

**សហព្រះរាជអាជ្ញា:**

ជា លាង
Nicholas KOUMJIAN

**ជនជាប់ចោទ**

ខៀវ សំផន
នួន ជា

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Marie GUIRAUD

**សហមេធាវីការពារក្តី នួន ជា**

សុន អរុណ
Victor KOPPE

**សហមេធាវីការពារក្តី ខៀវ សំផន**

គង់ សំអុន
Anta GUISSÉ
Arthur VERCKEN

១. **អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ("អង្គជំនុំជម្រះតុលាការកំពូល" ឬ"អង្គជំនុំជម្រះ" និង"អ.វ.ត.ក") បានទទួល "សំណើទីបីសុំឱ្យធ្វើការពិចារណា និងទទួលយកភស្តុតាងបន្ថែម ដែលជាប់ពាក់ព័ន្ធទៅនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ក្នុងសំណុំរឿង ០០២/០១" ដែលបានដាក់ដោយ នួន ជា នៅថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ("សំណើ")[1]។ សហព្រះរាជអាជ្ញា ដាក់សារណាតបនៅថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៤ ("សារណាតប")[2]។ សេចក្តីសម្រេចបច្ចុប្បន្ននេះ សម្រេចលើការស្នើសុំមួយនៃការស្នើសុំនានារបស់ នួន ជា ដែលមាននៅក្នុងសំណើនេះ ដែលស្នើសុំអង្គជំនុំជម្រះតុលាការកំពូល បង្គាប់ឱ្យសហព្រះរាជអាជ្ញាធ្វើការពិនិត្យមើលឡើងវិញលើសំណុំរឿង ០០៣ និង ០០៤ និងធ្វើការស្នើសុំការអនុញ្ញាតពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ស.ច.ស.អ") ក្នុងការបង្ហាញភស្តុតាងណាមួយដែល "(១) ត្រូវបានផ្តល់ឱ្យដោយសាក្សីដែលជាអ្នកធ្វើការផ្ទាល់ជាមួយ រស់ ញឹម នៅក្នុងអំឡុងពេលណាមួយនៃ របបកម្ពុជាប្រជាធិបតេយ្យ ឬ (២) មានការពាក់ព័ន្ធនឹងការប្រឆាំងរបស់ភូមិភាគពាយ័ព្យជាមួយ ប៉ុល ពត និង នួន ជា មុនថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩"[3]។

## ក. សាវតា

២. នៅថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូង បានចេញសាលក្រមក្នុងសំណុំរឿង ០០២/០១ ("សាលក្រមអង្គជំនុំជម្រះសាលាដំបូង")[4] ដោយផ្តន្ទាទោស ខៀវ សំផន និង នួន ជា ពីបទ

---

[1] ឯកសារ F2/4 ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៤ (សំណៅសម្ងាត់បំផុតត្រូវបានជូនដំណឹងមកភាគីនៅថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១៤។ សំណៅកោសលុបសម្រាប់សាធារណៈត្រូវបានជូនដំណឹងនៅថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៤)។ នួន ជា ដាក់សំណើពីរទៀតស្នើសុំភស្តុតាងបន្ថែម៖ *សូមមើល* សំណើសុំឱ្យទទួល និងពិចារណាទៅលើភស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០១ ឯកសារ F2 ចុះថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៤។ សំណើលើកទីពីរស្នើសុំឱ្យពិចារណាទៅលើភស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០១ ឯកសារ F2/1 ចុះថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ២០១៤ (សំណៅដែលបានកែប្រែត្រូវបានជូនដំណឹងនៅថ្ងៃទី ៣ ខែ កញ្ញា ឆ្នាំ ២០១៤)។

[2] សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើទីបីរបស់ នួន ជា សុំធ្វើការពិចារណា និងទទួលភស្តុតាងបន្ថែមពាក់ពន្ធ័នឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ក្នុងសំណុំរឿង ០០២/០១ (សម្ងាត់បំផុត) ឯកសារលេខ F2/4/1 ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៤ (ទោះបីជាមានសំណើសុំជាក់លាក់ពីអង្គជំនុំជម្រះនេះ ឱ្យដាក់សំណើដែលមានការកោសលប់នៃសារណាតបនេះ ដែលអាចត្រូវបានចាត់ថ្នាក់ជាសាធារណៈ ប៉ុន្តែកន្លងមកពុំបានទទួលការដាក់ឯកសារណាមួយពីសហព្រះរាជអាជ្ញាឡើយ)។

[3] សំណើ កថាខណ្ឌ ៣៣, ៣៤(គ)។

[4] សាលក្រមក្នុងសំណុំរឿង ០០២/០១ ឯកសារ E313 ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤។

ឧក្រិដ្ឋប្រឆាំងមនុស្សជាតិនៃការសម្លាប់រង្គាល (រួមទាំង ការធ្វើមនុស្សឃាត) ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (រួមមាន ការជម្លៀសដោយបង្ខំ ការបាត់ខ្លួនដោយបង្ខំ និងការធ្វើឲ្យប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មនុស្សជាតិ) និងបានផ្ដន្ទាទោសពួកគេម្នាក់ៗដាក់ពន្ធនាគារអស់មួយជីវិត[5]។ ការផ្ដន្ទាទោសទាំងនេះ គឺសំអាងលើបទចោទនានានៅក្នុងដីកាដំណោះស្រាយទាក់ទងនឹងតួនាទី និងមុខងាររបស់ ខៀវ សំផន និង នួន ជា នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា (“ប.ក.ក”) និងការទទួលខុសត្រូវព្រហ្មទណ្ឌទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី ១ និង ២) ព្រមទាំងការសម្លាប់រង្គាលអតីតមន្ត្រីសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃ[6]។

៣. នៅថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ នួន ជា និង ខៀវ សំផន បានដាក់សេចក្ដីជូនដំណឹងរបស់ខ្លួនស្ដីពីបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង[7]។ នៅថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ នួន ជា និង ខៀវ សំផន បានដាក់សារណាបណ្ដឹងសាទុក្ខរបស់ខ្លួនប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង[8]។

---

[5] សាលក្រមអង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦២២។

[6] *សូមមើល* សាលក្រមសាលាដំបូង កថាខណ្ឌ ១១, ១៦៨, ៤១០, ៤១៤, ៤២៥, ៤៣៤, ៤៤១, ៤៤៩, ៤៥៦, ៤៥៩, ៥៧៥, ៦៥៨ ដល់ ៦៥៩, ៧២២ ដល់ ៧២៣, ៨៣៨, ៩៤៣។ *សូមមើលផងដែរ* [កែតម្រូវលើកទីពីរ] បញ្ជីនៃកថាខណ្ឌ និងផ្នែកនានា នៃដីកាដំណោះស្រាយពាក់ពន្ធ័នឹងសំណុំរឿង ០០២/០១ ដែលត្រូវបានវិសោធនកម្មបន្ថែមលើសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីនីតិសម្បទារបស់អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ ឯកសារលេខ (E138) និង សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីសំណើរបស់សហព្រះរាជអាជ្ញាសុំបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមនៅក្នុងវិសាលភាពនៃការជំនុំជម្រះក្ដីក្នុងសំណុំរឿង ០០២/០១ ឯកសារលេខ (E163), E124/7.3, ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១២។

[7] សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ឯកសារ E313/1/1 ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤។ *សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដីលោក ខៀវ សំផន ប្រឆាំងនឹងសាលក្រមលើសំណុំរឿង ០០២/០១* ឯកសារ E313/2/1 ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤។ *សូមមើលផងដែរ* សេចក្ដីសម្រេចលើសំណើរបស់មេធាវីការពារក្ដីសុំពន្យាពេល និងបន្ថែមចំនួនទំព័រលើសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ និងសារណានៃបណ្ដឹងសាទុក្ខ ឯកសារ F3/3 ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៤។

[8] បណ្ដឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ឯកសារ F16 ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ (“សារណាលើបណ្ដឹងសាទុក្ខរបស់ នួន ជា”)។ *[Corrigé 1] Mémoire d’appel de la Défense de M. KHIEU Samphân contre le jugement rendu dans le procès 002/01* ឯកសារ F17 ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ (សំណៅដែលបានកែប្រែត្រូវបានដាក់នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤)។ *សូមមើលផងដែរ* សេចក្ដីសម្រេចលើសំណើរបស់មេធាវីការពារក្ដីសុំបន្ថែមចំនួនទំព័រ ដើម្បីប្ដឹងសាទុក្ខ និងបន្ថែមពេលវេលាដើម្បីដាក់សារណាតប ឯកសារ F13/2 ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៤។ សេចក្ដីសម្រេចលើសំណើសុំពន្យារយៈពេល និងបន្ថែមចំនួនទំព័រ សម្រាប់សារណាបណ្ដឹងសាទុក្ខ និងសារណាតប ឯកសារ F9 ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤។

៤. នៅក្នុងសំណើ នួន ជា ស្នើសុំធ្វើការកំណត់ និងទទួលយកជាភស្តុតាងទៅលើបណ្តឹងសាទុក្ខនូវភស្តុតាងណាមួយ នៅក្នុងសំណុំរឿង ០០៣ និង ០០៤ ដែលបច្ចុប្បន្នកំពុងស្ថិតក្រោមការស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេត ដែលភស្តុតាងនេះ អាចនឹងដោះបន្ទុក នួន ជា ដោយបង្ហាញថា បុគ្គលដទៃទៀត ជាអ្នកគ្រប់គ្រងលើឧក្រិដ្ឋកម្ម ដែលត្រូវបានផ្តន្ទាទោសនៅក្នុងសាលក្រម[9]។

## ខ. **<u>សារណា</u>**

៥. ជាពិសេស នួន ជា បានស្នើសុំឲ្យអង្គជំនុំជម្រះតុលាការកំពូល*ក្នុងនោះ* បង្គាប់ដល់សហព្រះរាជអាជ្ញាធ្វើការពិនិត្យមើលលើសំណុំរឿង ០០៣ និង ០០៤ ព្រមទាំងស្នើសុំការអនុញ្ញាតពី ស.ច.ស.អ ក្នុងការបង្ហាញនូវភស្តុតាងណាមួយដែលជាប់ពាក់ព័ន្ធ និងមានលក្ខណៈដោះបន្ទុកដូចមាននៅក្នុងសំណើនេះដែលត្រូវបាន"(១) ផ្តល់ឲ្យដោយសាក្សីដែលធ្វើការផ្ទាល់ជាមួយ រស់ ញឹម នៅអំឡុងពេលណាមួយក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឬ (២) ពាក់ព័ន្ធនឹងការប្រឆាំងរបស់ភូមិភាគពាយ័ព្យជាមួយ ប៉ុល ពត និង នួន ជា មុនថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩"[10]។

៦. នួន ជា រំលឹកឡើងវិញថា សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") បានបង្ហាញនូវភស្តុតាងពីសំណុំរឿង ០០៤ ដោយចង្អុលបញ្ជាក់ថា ភស្តុតាងនេះ មានការពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០២ ដែលបច្ចុប្បន្នកំពុងជំនុំជម្រះ[11]។ នួន ជា បានលើកឡើងថា ជាការពិត ផ្នែកមួយនៃភស្តុតាងនោះ គឺជាប់ពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១[12] ហើយបានកត់សម្គាល់ថា "សូម្បីតែបច្ចុប្បន្ននេះ ក៏សហព្រះរាជអាជ្ញាអន្តរជាតិពុំបានជូនដំណឹងដល់ភាគីអំពីភាពពាក់ព័ន្ធនៃ [...] ភស្តុតាងក្នុងសំណុំរឿង ០០២/០១ ដែរ"[13]។ ផ្អែកលើមូលដ្ឋាននេះ នួន ជា បានលើកឡើងថា "អត្ថិភាពនៃភស្តុតាងពាក់ព័ន្ធដទៃទៀតក្នុងសំណុំរឿង ០០៣ ឬ សំណុំរឿង ០០៤ ដែលសហព្រះរាជអាជ្ញាអន្តរជាតិពុំបានចាត់ទុកថា មានភាពពាក់ព័ន្ធជាមួយនឹងបទចោទក្នុងសំណុំរឿង ០០២/០១ ទេនោះ បានបង្ហាញក្នុងកម្រិតអប្បបរមានូវលទ្ធភាពអាចកើតមាន"[14]។ នួន ជា ក៏បានលើកជាទឡ្ហីករណ៍ថា សំណើសុំរបស់ខ្លួនក្នុងការបង្ហាញនូវភស្តុតាងនេះ គឺមានភាពជាក់

---

[9] សំណើ កថាខណ្ឌ ៣, ១៨ ដល់ ២០, ២៤ ដល់ ២៥ និង ៣៣ ដល់ ៣៤។

[10] សំណើ កថាខណ្ឌ ៣៣ ដល់ ៣៤ ។

[11] សំណើ កថាខណ្ឌ ៦ និង២៩។

[12] សំណើ កថាខណ្ឌ ៣០។

[13] សំណើ កថាខណ្ឌ ៣១។

[14] សំណើ កថាខណ្ឌ ៣៣។

លាក់គ្រប់គ្រាន់ ដូចដែលបានតម្រូវដោយយុត្តិសាស្ត្រអន្តរជាតិ[15]។

៧. សហព្រះរាជអាជ្ញា ស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលច្រានចោលសំណើនេះទាំងមូល[16]។ សហព្រះរាជអាជ្ញាបានលើកឡើងថា សំណើនេះ គឺមានលក្ខណៈជាការប៉ាន់ស្មាន ពុំបានតំណាងឱ្យអង្គហេតុ និងទំនងជាពុំបានបង្ហាញភស្តុតាងដោះបន្ទុកឡើយ[17]។ សហព្រះរាជអាជ្ញា បានប្រកាសថា ខ្លួន បានពិនិត្យគ្រប់ជ្រុងជ្រោយរួចហើយទៅលើសំណុំរឿង ០០៣ និង សំណុំរឿង ០០៤ បានកំណត់អត្តសញ្ញាណឯកសារជាង ៣០០ ដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២ និងបានស្នើសុំ ស.ច.ស.អ អនុញ្ញាតឲ្យដាក់បង្ហាញឯកសារទាំងនោះ[18]។ ហេតុនេះ សហព្រះរាជអាជ្ញាឃើញថា ពុំមានភាពចាំបាច់ក្នុងការពិនិត្យមើលបន្ថែមទៅលើសំណុំរឿងនេះទេ[19]។ ជាងនេះទៀត សហព្រះរាជអាជ្ញាបានអះអាងថា ប្រភេទនៃភស្តុតាងដែល នួន ជា ស្នើសុំនោះ ពុំមានតម្លៃដោះបន្ទុកឡើយ ដោយហេតុថា ការបែកបាក់នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ដែលមេធាវីការពារក្តីចង់បង្ហាញនោះ បានកើតឡើងក្នុងរយៈប៉ុន្មានជាច្រើនឆ្នាំ ក្រោយពេលការប្រព្រឹត្តនៃឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់ក្នុងសំណុំរឿង ០០២/០១ មកម្ល៉េះ ដូច្នេះហើយ វាពុំបានគាំទ្រដល់ការជំទាស់របស់មេធាវីការពារក្តីឡើយ ដែលថា រស់ ញឹម បានប្រព្រឹត្តនូវបទឧក្រិដ្ឋដោយឯករាជ្យ ហើយទំលាក់កំហុសមកលើ នួន ជា វិញ[20]។ ចុងក្រោយ ក្នុងការឆ្លើយតបទៅនឹងការអះអាងរបស់ នួន ជា ដែលថា សហព្រះរាជអាជ្ញា ពុំបានអនុវត្តតាមឲ្យបានពេញលេញចំពោះកាតព្វកិច្ចនៃការដាក់បង្ហាញភស្តុតាងរបស់ខ្លួន[21] សហព្រះរាជអាជ្ញារម្លឹកឡើងវិញពី "កិច្ចខិតខំប្រឹងប្រែងយ៉ាងហ្មត់ចត់របស់ខ្លួន ក្នុងការទទួលបាននូវការអនុញ្ញាត ដើម្បីបង្ហាញ [...] ក្នុងការស្តាប់ចម្លើយសាក្សីក្នុងសំណុំរឿង ០០៣ និង ០០៤"[22] និងបានអះអាងជាថ្មីនូវភាពពាក់ព័ន្ធនឹងសម្ភារៈដែលត្រូវបានបង្ហាញទៅនឹងសំណុំរឿង ០០២/០២[23]។

## គ. ការពិភាក្សា

[15] សំណើ កថាខណ្ឌ ៣២ ដល់ ៣៣។

[16] សារណាតប កថាខណ្ឌ ១៨។

[17] សារណាតប កថាខណ្ឌ ៥ ដល់ ១០។

[18] សារណាតប កថាខណ្ឌ ១១ ដល់ ១២, ១៤។

[19] សារណាតប កថាខណ្ឌ ១៥។

[20] សារណាតប កថាខណ្ឌ ៥ ដល់ ៦, ១៥, ១៧។

[21] សំណើ កថាខណ្ឌ ៣១។

[22] សារណាតប កថាខណ្ឌ ១៣។

[23] សារណាតប កថាខណ្ឌ ១១ ដល់ ១៤។

**១. សំណើសុំឱ្យបង្គាប់ដល់សហព្រះរាជអាជ្ញាធ្វើការពិនិត្យឡើងវិញលើសំណុំរឿង ០០៣ និង ០០៤**

**និងធ្វើការស្នើសុំការអនុញ្ញាតដាក់បង្ហាញភស្តុតាងដោះបន្ទុកដែលមានសក្តានុពល**

៨. យោងតាមឯកសារនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល[24]នៅថ្ងៃទី ១ ឬ ២ ខែ ឧសភា ឆ្នាំ ២០១៤ ស.ព.អ បានស្នើសុំការអនុញ្ញាតដើម្បីបង្ហាញកំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួន ២៣១ ("កំណត់ហេតុស្តាប់ចម្លើយសាក្សី") ពីសំណុំរឿង ០០៤ មកក្នុងសំណុំរឿង ០០២/០២[25]។ នៅថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ ២០១៤ ស.ព.អ ស្នើសុំការដាក់បង្ហាញបន្ថែមនូវការស្តាប់ចម្លើយសាក្សី និងឯកសារផ្សេងទៀតចំនួន ៩៤[26]។ នៅថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៤ ស.ច.ស.អ បានបដិសេធសំណើនេះ[27]ថា ពុំទាន់ដល់ពេលត្រូវបង្ហាញ ដោយហេតុថា ការចាប់ផ្តើមសវនាការលើសំណុំរឿង ០០២/០២ មិនទាន់ត្រូវបានកំណត់កាលបរិច្ឆេទនៅឡើយ[28]។

៩. នៅថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូង បានចេញដីកាកំណត់កាលបរិច្ឆេទនៃសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២[29]។ នៅថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ និងនៅថ្ងៃទី ៩ ខែ តុលា ឆ្នាំ ២០១៤ ស.ព.អ បានអះអាងជាថ្មីពីសំណើរបស់ខ្លួនដែលបានដាក់ទៅ ស.ច.ស.អ ដោយសុំការអនុញ្ញាតបង្ហាញការស្តាប់ចម្លើយសាក្សីចំនួន ២៧ នៅក្នុងសំណុំរឿង ០០៤ ដែលត្រូវបានចាត់ទុកថាមានការជាប់ពាក់ព័ន្ធនឹងវគ្គទីមួយនៃការជំនុំជម្រះក្តីក្នុងសំណុំរឿង ០០២/០២[30]។ ស.ព.អ បានចង្អុលបង្ហាញថា ការស្តាប់ចម្លើយទាំងនោះ គឺសំដៅទៅលើបុគ្គលដែលទំនងជាអាចនឹងត្រូវបានកោះហៅមក

---

[24] *សូមមើល* ដីកាបង្គាប់ឱ្យអនុវត្តភ្លាមៗតាមវិធាន ១០៨ នៃវិធានផ្ទៃក្នុង ឯកសារលេខ E238/9/1/4 ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៣។

[25] ដីកាសម្រេចលើសំណើបន្ទាន់របស់សហព្រះរាជអាជ្ញា សុំដាក់បង្ហាញការស្តាប់ចម្លើយសាក្សីក្នុងសំណុំរឿង ០០៤ នៅក្នុងវគ្គទីមួយ នៃការជំនុំជម្រះក្តីក្នុងសំណុំរឿង ០០២/០២ (សម្ងាត់បំផុត) ឯកសារ E319.2 ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៤ ("ដីកាសម្រេចដាក់បង្ហាញលើកទី១") កថាខណ្ឌ ២ *ប្រៀបធៀបនឹង*សារណាតប កថាខណ្ឌ ១១។

[26] សារណាតប កថាខណ្ឌ ១១។

[27] ពីក្នុងចំណោមឯកសារដែលមានក្នុងដៃអង្គជំនុំជម្រះនេះ មិនមានភាពច្បាស់លាស់ថាតើនៅថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៤ ស.ច.ស.អ បានបដិសេធសំណើទាំងពីរ ឬបានឆ្លើយតបទៅលើសំណើទី១ ដែរ ឬយ៉ាងណាទេ (ប្រៀបធៀប ចម្លើយតប កថាខណ្ឌ ១១ និង ដីកាសម្រេចដាក់បង្ហាញលើកទី១ កថាខណ្ឌ ៣)។ ក្នុងកាលៈទេសៈណាក៏ដោយ ពិតជាច្បាស់លាស់ដែលថា ការដាក់បង្ហាញសម្ភារៈណាមួយក្នុងសវនាការលើសំណុំរឿង ០០២/០២ ពុំត្រូវបានអនុញ្ញាតដោយ ស.ច.ស.អ មុនដីកាសម្រេចដាក់បង្ហាញលើកទី ១ ឡើយ។

[28] ដីកាសម្រេចដាក់បង្ហាញលើកទី ១ កថាខណ្ឌ ៣។

[29] សារណាតប កថាខណ្ឌ ១២ (ដកស្រង់ពីដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២ ឯកសារ E316 ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៤)។

[30] ដីកាសម្រេចដាក់បង្ហាញលើកទី ១ កថាខណ្ឌ ៦ ដល់ ៨។

ផ្តល់សក្ខីកម្មក្នុងវគ្គទីមួយនៃការជំនុំជម្រះក្តីក្នុងសំណុំរឿង ០០២/០២ ឬ សំដៅលើបុគ្គលដែលការស្តាប់ចម្លើយរបស់បុគ្គលនេះ “គឺពិតជាសំខាន់ណាស់”ចំពោះភាគីនានាក្នុងសំណុំរឿង ០០២/០២[31]។

១០. នៅថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៤ ស.ច.ស.អ បានចេញដីកាសម្រេចស្តីពីការបង្ហាញភស្តុតាងលើកទី១[32] ដោយអនុញ្ញាតក្រោមលក្ខខណ្ឌតឹងរ៉ឹងឲ្យធ្វើការបង្ហាញនូវកំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួន ៣៣ ដែលទទួលបានពីសាក្សីចំនួន ២៦ នាក់ ពីសំណុំរឿង ០០៤ ទៅអង្គជំនុំជម្រះសាលាដំបូង និងភាគីនានាក្នុងសំណុំរឿង ០០២/០២[33]។

១១. នៅថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ស.ច.ស.អ បានអនុញ្ញាតឲ្យធ្វើការបង្ហាញកំណត់ហេតុស្តាប់ចម្លើយសាក្សីមួយបន្ថែមទៀត ដែលពុំត្រូវបានអនុញ្ញាតដោយដីកាសម្រេចស្តីពីការបង្ហាញភស្តុតាងលើកទី ១ ហើយ បន្ទាប់ពីមានសំណើពី ស.ព.អ ក៏បានអនុញ្ញាតឱ្យបង្ហាញនូវកំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួន ៣ ដែលទើបនឹងបញ្ចូលថ្មីទៅក្នុងសំណុំរឿង ០០៤ ដែលត្រូវចាត់ទុកថាពាក់ព័ន្ធនឹងវគ្គទីមួយនៃការជំនុំជម្រះក្តីក្នុងសំណុំរឿង ០០២/០២[34]។

១២. នៅថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥ ស.ច.ស.អ បានទទួលយកផ្នែកខ្លះនៃសំណើមួយបន្ថែមរបស់ ស.ព.អ ដោយអនុញ្ញាតឲ្យធ្វើការបង្ហាញនូវកំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួន ២០ បន្ថែមទៀតពីក្នុងសំណុំរឿង ០០៤ រួមមានការស្តាប់ចម្លើយសាក្សីដែល ស.ព.អ បានធ្វើការពិចារណាថា ស្ថិតក្នុងវិសាលភាពនៃសំណើសុំរបស់ នួន ជា[35]។

---

[31] ដីកាសម្រេចដាក់បង្ហាញលើកទី ១ កថាខណ្ឌ ១០ ដល់ ១៤។

[32] *សូមមើល* ខាងលើ ជើងទំព័រ ២៥។

[33] ដីកាសម្រេចដាក់បង្ហាញលើកទី ១ កថាខណ្ឌ ២៣ ( ប្រៀបធៀប*ដូចគ្នា* កថាខណ្ឌ ៨ ដល់ ១៤ ដែលក្នុងនោះ មានភាពពុំស៊ីសង្វាក់គ្នាជាច្រើន ដូចជា ចំនួនជាក់ស្តែងនៃកំណត់ហេតុស្តាប់ចម្លើយដែលបានអនុញ្ញាតឱ្យធ្វើការបង្ហាញ និងចំនួនសាក្សីដែលបានផ្តល់នូវកំណត់ហេតុស្តាប់ចម្លើយនេះ), សារណាតប កថាខណ្ឌ ១២។

[34] ដីកាសម្រេចលើសំណើបន្ទាន់របស់សហព្រះរាជអាជ្ញា សុំដាក់បង្ហាញការស្តាប់ចម្លើយសាក្សីដែលទើបបញ្ចូលថ្មីៗទៅក្នុងសំណុំរឿង ០០៤ នៅក្នុងវគ្គទីមួយ នៃការជំនុំជម្រះក្តីក្នុងសំណុំរឿង ០០២/០២ (សម្ងាត់បំផុត) ឯកសារ E319/8.3 ចុះថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤ (“ដីកាសម្រេចដាក់បង្ហាញលើកទី ២”) កថាខណ្ឌ ១៣។

[35] ដីកាសម្រេចផ្នែកខ្លះលើសំណើរបស់សហព្រះរាជអាជ្ញាសុំដាក់បង្ហាញឯកសារស្តាប់ចម្លើយសំណុំរឿង ០០៤ ដែលពាក់ព័ន្ធនឹងសវនាការនៃសំណុំរឿង ០០២/០២ និងបណ្តឹងសាទុក្ខនៃសំណុំរឿង ០០២/០១ ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E319/12.1.1 ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៥ ដូចដែលត្រូវបានកែប្រែដោយ ការកែប្រែដីកាសម្រេចដាក់បង្ហាញឯកសារ D193/4, D193/6 និង D193/8 (សម្ងាត់បំផុត) ឯកសារ E319/12.1.2 ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៥ (“ដីកាសម្រេចដាក់បង្ហាញលើកទី ៣”)។

១៣. នៅថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ ស.ច.ស.អ បានផ្តល់ការអនុញ្ញាតឲ្យធ្វើការបង្ហាញនូវកំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួន ៩០ បន្ថែមទៀតពីសំណុំរឿង ០០៤ រួមទាំងចម្លើយសាក្សីដែលមិនត្រូវបានបង្ហាញពីមុន ដែល ស.ព.អ ចាត់ទុកថា ស្ថិតក្នុងវិសាលភាពនៃសំណើនេះ[36]។

១៤. នៅថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៥ ស.ព.អ បានប្រកាសនៅក្នុងបរិបទនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ ថា ឯកសារប្រមាណ ១៩០ ដែលនឹងត្រូវធ្វើការបង្ហាញ កំពុងស្ថិតនៅក្នុងសំណើសុំនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត[37]។

១៥. នៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៥ ស.ច.ស.អ បានអនុញ្ញាតឲ្យធ្វើការបង្ហាញនូវកំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួន ៥ ដែលទាក់ទងទៅនឹងសាក្សីម្នាក់[38]។

១៦. ស.ព.អ បានស្នើសុំ ហើយអង្គជំនុំជម្រះសាលាដំបូងបានអនុញ្ញាត ឲ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីមួយចំនួនធំ មកក្នុងសំណុំរឿង ០០២/០២ ដើម្បីបង្ហាញដល់ភាគី[39]។

---

[36] ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញឯកសារ D193/7 និង D193/9 សម្រាប់សំណុំរឿង ០០២ (សម្ងាត់បំផុត) ឯកសារ E319/13.1.1 ចុះថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ ២០១៥ ("ដីកាសម្រេចដាក់បង្ហាញលើកទី៤") កថាខណ្ឌ ៨, ៩, ១១ (ឯកសារចំនួន ៨៧ ក្នុងចំណោមកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលបានដាក់បង្ហាញ ត្រូវបានកំណត់អត្តសញ្ញាណដោយ ស.ព.អ នៅក្នុងសំណើរបស់ខ្លួននៅថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៥ ដែលត្រូវបានទទួលយកតែផ្នែកខ្លះដោយដីកាសម្រេចដាក់បង្ហាញលើកទី ៣ ។ ឯកសារចំនួន ៣ ក្នុងចំណោមកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលត្រូវបានកំណត់អត្តសញ្ញាណក្នុងសំណើរបស់ ស.ព.អ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៦។ តួលេខដែលត្រូវបានពិចារណាដោយអង្គជំនុំជម្រះតុលាការកំពូល ពុំបានបញ្ចូលសំណើសុំការកែតម្រូវទេ)។

[37] ព័ត៌មាន និងការបំភ្លឺអំពីដំណើរការនៃការដាក់បង្ហាញឯកសារក្នុងសំណុំរឿង ០០២/០២ ក្នុងបរិបទនៃកិច្ចស៊ើបសួរដែលកំពុងធ្វើនៃសំណុំរឿង ០០៣ និង ០០៤ ឯកសារ E319/14 ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៥ ("ព័ត៌មានរបស់ ស.ព.អ ស្តីពីការដាក់បង្ហាញ") កថាខណ្ឌ ៨។

[38] ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញក្នុងសំណុំរឿង ០០២ ពាក់ព័ន្ធនឹងសាក្សីម្នាក់ (សម្ងាត់បំផុត) ឯកសារ E319/15.1 ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១៥ ("ដីកាសម្រេចដាក់បង្ហាញលើកទី៥") កថាខណ្ឌ ៨។

[39] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឲ្យទទួលយកឯកសារដែលទាក់ទងនឹងសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ អនុលោមតាមវិធាន ៨៧(៣) និង ៨៧(៤) ឯកសារ E319/5 ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤។ សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឲ្យទទួលយកឯកសារដែលទាក់ទងនឹងសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ និងសេចក្តីបង្គាប់ស្តីពីការប្រើប្រាស់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីក្នុងសំណុំរឿង ០០៣ និង ០០៤ ឯកសារ E319/7 ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៤។ ការដាក់បង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិ នូវកំណត់ហេតុស្តាប់ចម្លើយសាក្សីពីសំណុំរឿង ០០៤ និងពាក់ព័ន្ធនឹងវគ្គទីមួយ នៃសវនាការក្នុងសំណុំរឿង ០០២/០២ ឯកសារ E319/8 ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥។ សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឲ្យទទួលយកឯកសារដែលទាក់ទងនឹងសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ អនុលោមតាមវិធាន ៨៧(៣) និង ៨៧(៤)

១៧. អង្គជំនុំជម្រះតុលាការកំពូលរំលឹកថា សហព្រះរាជអាជ្ញា ស្ថិតក្រោមកាតព្វកិច្ចដែលតម្រូវឱ្យបន្តដាក់បង្ហាញដល់អង្គជំនុំជម្រះ និងភាគីនូវ"សម្ភារៈទាំងឡាយណាដែលខ្លួនមាន ដែលអាចបង្ហាញនូវនិរទោស ឬអាចសម្រាលនូវពិរុទ្ធភាពរបស់ជនជាប់ចោទ ឬមានឥទ្ធិពលទៅលើភាពអាចជឿជាក់បាននៃភស្តុតាង"ដូចដែលត្រូវបានកំណត់ដោយវិធាន ៥៣(៤) នៃវិធានផ្ទៃក្នុង[40]។ កាតព្វកិច្ចនេះ គឺជាសមាសភាគមួយនៃការជំនុំជម្រះប្រកបដោយយុត្តិធម៌ ស្របទៅនឹងតួនាទីរបស់អយ្យការ ដើម្បីជួយដល់តុលាការក្នុងការស្វែងរកការពិត[41]។ ហេតុដូច្នេះ កាតព្វកិច្ចនេះ លាតសន្ធឹងទៅដល់កិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ[42]។

---

ឯកសារ E319/11 ចុះថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ ២០១៥។ ការដាក់បង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិ នូវឯកសារមួយចំនួនពីសំណុំរឿង ០០៤ និងពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២ ឯកសារ E319/12 ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៥ ("សំណើរបស់ ស.ព.អ ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៥")។ ការដាក់បង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិ នូវឯកសារមួយចំនួនពីសំណុំរឿង ០០៤ និងពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២ អនុលោមតាមសំណុំរឿង០០៤-D193/11 ឯកសារ E319/13 ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៥ ("សំណើរបស់ ស.ព.អ ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៥")។ ការដាក់បង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិ នូវឯកសារមួយចំនួនពីសំណុំរឿង ០០៤ និងពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២ អនុលោមតាមសំណុំរឿង០០៤-D193/13 ឯកសារ E319/15 ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៥។ *សូមមើលផងដែរ* សំណើសុំដាក់បង្ហាញបទសម្ភាសន៍សម្ងាត់ក្នុងសំណុំរឿង ០០៤ ដល់មេធាវីប្រចាំការ ឯកសារ E319/9 ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៥។

40 អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា "ការជូនដំណឹងអំពីចម្លើយសាក្សីសម្រាប់សាក្សីដែលអាចផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២" ឯកសារ E127/4 ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១២។

41 *សូមមើល* ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៤។ *សូមមើលផងដែរ* សេចក្តីសម្រេចលើសំណើសុំរួមគ្នារបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំការសម្រេចលើឋានៈរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការធ្វើសេចក្តីសន្និដ្ឋានលើផ្នែកប្រកាសទោស និងការណែនាំទាក់ទងនឹងការសួរជនជាប់ចោទ អ្នកជំនាញ និងសាក្សីដែលផ្តល់សក្ខីកម្មលើអត្តចរិក ឯកសារលេខ E72/3, ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៩ កថាខណ្ឌ ២៤ ដល់ ២៥ (មតិជំទាស់របស់ចៅក្រម Lavergne, ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង)។

42 *សូមមើល ឧទាហរណ៍* តុលាការព្រហ្មទណ្ឌអន្តរជាតិ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Katanga និង Ngudjolo Chui* សំណុំរឿងលេខ ICC-01/04-01/07-621 "សេចក្តីសម្រេចលើឯកសារដែលត្រូវបានកំណត់អត្តសញ្ញាណថាដោះបន្ទុកយ៉ាងមានសក្តានុពល តាមមាត្រា ៥៤ (៣)(ង) ឬ សម្ភារៈផ្សេងទៀតដើម្បីឱ្យមេធាវីការពារក្តីត្រៀមរៀបចំសម្រាប់សវនាការបំភ្លឺ" អង្គបុរេជំនុំជម្រះ I ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ កថាខណ្ឌ ៣។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ("ICTY") *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Blaškić* សំណុំរឿងលេខ IT-95-14-A "សេចក្តីសម្រេចលើញត្តិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ស្នើសុំការបង្ហាញសម្ភារៈ ការផ្អាក ឬការពន្យាពេលកាលបរិច្ឆេទដាក់សារណា និងការដាក់ឯកសារបន្ថែមទៀត" អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០០០ កថាខណ្ឌ ៣២, ៣៧, ៤២។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វាន់ដា ("ICTR") *រឿងក្តី Ndindabahizi ទល់នឹង រដ្ឋអាជ្ញា* សំណុំរឿងលេខ ICTR-01-71-A "សាលដីកា" អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០០៧ កថាខណ្ឌ ៧២ និង តុលាការ ICTY *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Kordić និង Čerkez* សំណុំរឿងលេខ IT-95-14/2-A "សាលដីកា" អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៤ កថាខណ្ឌ ១៨៣, ២៤២ (ដោយប្រកាសថា កាតព្វកិច្ចរបស់រដ្ឋអាជ្ញាក្នុងការដាក់បង្ហាញសម្ភារៈ

១៨. សហព្រះរាជអាជ្ញាបានលើកឡើងថា ខ្លួនបានលះបង់“ពេលវេលា និងធនធានយ៉ាងច្រើន” ដើម្បីធ្វើការពិនិត្យពិច័យជាប្រព័ន្ធ និងស៊ីជម្រៅទៅលើសំណុំរឿង ០០៣ និង សំណុំរឿង ០០៤[43] ហើយ បានអះអាងបន្ថែមទៀតដល់ភាគីថា ខ្លួននឹងបន្តធ្វើដូចនេះជាបន្តទៀតពាក់ព័ន្ធនឹងសម្ភារៈដែលនឹងដាក់បញ្ចូលក្នុងសំណុំរឿង ០០៣ និង ០០៤ នាពេលអនាគត រហូតដល់ពេលបញ្ចប់នៃកិច្ចស៊ើបសួរក្នុងសំណុំរឿងទាំងនេះ[44]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា កំណត់ហេតុដែលអង្គជំនុំជម្រះនេះអាចចូលពិនិត្យមើលបានបង្ហាញថា ការពិនិត្យបឋមរបស់ ស.ព.អ ទៅលើសំណុំរឿង គឺមានគោលដៅដើម្បីកំណត់អត្តសញ្ញាណភស្តុតាងដែលជាប់ពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២ ហើយមិនជាប់ពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ ឡើយ[45]។ ជាងនេះទៅទៀត ទំនងជាលេចឡើងនូវករណីដែលថា ក្នុងចំណោមឯកសារចំនួន ៣២៥ ដែល ស.ព.អ បានកំណត់អត្តសញ្ញាណបឋមនោះ ស.ព.អ បានផ្តល់អាទិភាពក្នុងការដាក់បង្ហាញនូវឯកសារទាំងនោះ ដែលត្រូវបានពិចារណាថា មានភាពពាក់ព័ន្ធដោយផ្ទាល់ទៅនឹងទឡ្ហីករណ៍ ដែលកំពុងត្រូវបានធ្វើការជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០២។ មានតែសំណើមួយគត់ក្នុងចំណោមសំណើនានាក្នុងពេលបច្ចុប្បន្នរបស់ជនជាប់ចោទ ដែលបានស្នើឡើង បន្ទាប់ពីបានដាក់សំណើនេះ បានស្នើសុំឱ្យទទួលស្គាល់នូវភាពចាំបាច់ក្នុងការពិចារណាអំពីភាពពាក់ព័ន្ធទៅនឹងបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១[46]។ ដូចនេះ ដោយសំអាងលើបញ្ហានេះ វិសាលភាពនៃការត្រួតពិនិត្យជាបឋម ដែលត្រូវបានធ្វើឡើងដោយ ស.ព.អ នោះ អាចនឹងត្រូវបានកម្រិតត្រឹមបញ្ហាដែលជាប់ពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២។ ហេតុនេះ ពុំអាចច្រានចោលបាននូវករណីដែលថា សំណុំរឿង ០០៣ និង ០០៤ នៅតែមាន

---

ដោះបន្ទុក “មិនមែនជាកាតព្វកិច្ចបន្ទាប់បន្សំទេ ហើយវាសំខាន់ដល់កាតព្វកិច្ចចោទប្រកាន់ដែរ)។ តុលាការ ICTR *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Karemera និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ICTR-98-44-AR73.7 “សេចក្តីសម្រេចលើបណ្តឹងសាទុក្ខបន្ទាន់បន្ទំ ពាក់ព័ន្ធនឹងតួនាទីរបស់រដ្ឋអាជ្ញាក្នុងការដាក់បង្ហាញសម្ភារៈជាសំណៅអេឡិចត្រូនិក ក្នុងការអនុវត្តកាតព្វកិច្ចដាក់បង្ហាញ” អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៦ កថាខណ្ឌ ៩។

[43] សារណាតប កថាខណ្ឌ ១៤។

[44] សារណាតប កថាខណ្ឌ ១៤។

[45] ដីកាសម្រេចដាក់បង្ហាញលើកទី ១ កថាខណ្ឌ ២។ ពាក់ព័ន្ធនឹងសំណើរបស់ ស.ព.អ ថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ ២០១៤ អង្គជំនុំជម្រះនេះពុំមានព័ត៌មានដែលពាក់ព័ន្ធនឹងចំណងជើង ឬខ្លឹមសាររបស់វាទេ ដោយសារសំណើមិនត្រូវបានលើកឡើងនៅក្នុងដីកាសម្រេចដាក់បង្ហាញលើកទី១។ ទោះជាយ៉ាងណា អង្គជំនុំជម្រះសន្មតថា កម្មវត្ថុនៃសំណើនេះស្រដៀងគ្នាទៅនឹងសំណើថ្ងៃទី ១ ឬ ២ ខែ ឧសភា ឆ្នាំ ២០១៤ ដែរ (*សូមមើល* ចម្លើយតប កថាខណ្ឌ ១១)។

[46] សំណើរបស់ ស.ព.អ ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៥ កថាខណ្ឌ ១, ២ (ដោយបានថ្លែងថា នៅថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៤ ស.ព.អ បានស្នើសុំការអនុញ្ញាតឱ្យដាក់បង្ហាញឯកសារដែល នួន ជា ជឿថា មានភាពពាក់ព័ន្ធ នឹងមានភាពដោះបន្ទុកចំពោះបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១)។ *សូមមើលផងដែរ* ព័ត៌មានរបស់ ស.ព.អ ស្តីពីការដាក់បង្ហាញ កថាខណ្ឌ ៧។

សម្ភារៈដែលអាចជាប់ពាក់ព័ន្ធទៅនឹងការការពារខ្លួនរបស់ នួន ជា ក្នុងសំណុំរឿង ០០២/០១ ហើយពិសេសជាងនេះទៅទៀត បង្កើតបានជាភស្តុតាង ដែល"(១) ត្រូវបានផ្តល់ឱ្យដោយសាក្សី ដែលបានធ្វើការផ្ទាល់ជាមួយ រស់ ញឹម នៅអំឡុងពេលណាមួយក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឬ (២) ពាក់ព័ន្ធនឹងការប្រឆាំងរបស់ភូមិភាគពាយ័ព្យទៅនឹង ប៉ុល ពត និង នួន ជា មុនថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩"។ គួរកត់សម្គាល់ផងដែរ សារណាតបពុំបានលើកឡើងថា បន្ទាប់ពីការពិនិត្យពិច័យលើសំណុំរឿង ០០៣ និង ០០៤ រួចមក សហព្រះរាជអាជ្ញា ធ្វើការច្រានចោលនូវករណីដែលថា សំណុំរឿងទាំងនេះ មានសម្ភារៈ ទាំងអស់នេះឡើយ។

១៩. សហព្រះរាជអាជ្ញាអះអាងថា កម្មវត្ថុនានាដែលបានកំណត់ដោយ នួន ជា មិនមានភាពពាក់ព័ន្ធ និងមិនមានភាពដោះបន្ទុកចំពោះទឡ្ហីករណ៍នៅក្នុងសំណុំរឿង ០០២/០១ ឡើយ។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់លើសេចក្តីសន្និដ្ឋានបែបនេះ។ តែបើទោះជាយ៉ាងណាក៏ដោយ ដូចដែល នួន ជា បានលើកជាទឡ្ហីករណ៍[47] អង្គជំនុំជម្រះយល់ឃើញថា នៅក្នុងដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនេះ វាជាការគ្រប់គ្រាន់សម្រាប់ឱ្យមេធាវីការពារក្តីក្នុងការបង្ហាញ*តាមសេចក្តីបញ្ជាក់បឋម*ឃើញថា សម្ភារៈនេះ អាចមានតម្លៃដោះបន្ទុក ឬបន្ធូរបន្ថយទោសក្នុងការពារពារក្តី។ ដោយពិចារណាឃើញថា ការជំទាស់ដ៏សំខាន់របស់ នួន ជា គឺថា ប.ក.ក គឺជាបក្សមួយដែលមានការបែកជាច្រើនបំណែក ដោយ រស់ ញឹម ជាអ្នកមានសិទ្ធិអំណាចឯករាជ្យទៅលើឧក្រិដ្ឋកម្មនានាដែលត្រូវបានទម្លាក់មកលើ នួន ជា នៅក្នុងសាលក្រមសាលាដំបូង[48]នោះ សម្ភារៈដែលបានលើកឡើងក្នុងសំណើនេះ នឹងត្រូវដាក់បង្ហាញដោយអនុលោមតាម វិធាន ៥៣(៤) នៃវិធានផ្ទៃក្នុង ហើយ ក្នុងករណីដែលសម្ភារៈនេះពុំត្រូវបានបង្ហាញពីពេលមុនមកទេនោះ គឺត្រូវបង្ហាញនៅក្នុងពេលបណ្តឹងសាទុក្ខ។ ការយល់ឃើញនេះ គឺពុំមានការប៉ះពាល់ដល់សេចក្តីសម្រេចជាសក្តានុពលណាមួយនាពេលអនាគត ទាក់ទងទៅនឹងបញ្ហា ថាតើ សម្ភារៈនេះ បានបំពេញតាមលក្ខខណ្ឌតម្រូវនៃវិធាន ១០៨(៧) នៃវិធានផ្ទៃក្នុង ដែរ ឬយ៉ាងណា ប្រសិនបើភាគីណាមួយ ស្នើសុំឱ្យទទួលយកជាភស្តុតាងនោះ។

**២០.** ដោយហេតុថា អង្គជំនុំជម្រះតុលាការកំពូល ពុំបានបង្ខំឱ្យសហព្រះរាជអាជ្ញាធ្វើតាមវិធីសាស្ត្របែបណាឡើយ អង្គជំនុំជម្រះតុលាកំពូល បង្គាប់ឱ្យសហព្រះរាជអាជ្ញាបញ្ជាក់ឱ្យច្បាស់លើបញ្ហាថាតើ សំណុំរឿង ០០៣ និង ០០៤ មានសម្ភារៈទាំងនោះ ដែលបានស្នើឡើងនៅក្នុងសំណើនេះ ដែរ ឬយ៉ាងណា ហើយប្រសិនបើមាន ត្រូវស្នើសុំការអនុញ្ញាតពីសហចៅក្រមស៊ើបអង្កេត ដើម្បីធ្វើការបង្ហាញដល់អង្គជំនុំជម្រះ

[47] សំណើ កថាខណ្ឌ ៣២។

[48] *សូមមើលជាឧ.* សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៦២។ សំណើ កថាខណ្ឌ ២៤ ដល់ ២៦ និង ៣១។

និងភាគី។

## ២. នីតិវិធីពាក់ព័ន្ធនឹងភស្តុតាងដែលអាចដាក់បង្ហាញបាន ដែលមិនទាន់ត្រូវបាន អនុញ្ញាតដោយ ស.ច.ស.អ

២១. បញ្ហាពាក់ព័ន្ធដែល អង្គជំនុំជម្រះត្រូវធ្វើការដោះស្រាយទៅតាមការផ្តួចផ្តើមគំនិតរបស់ខ្លួន ដែលជាផ្នែកមួយនៃកាតព្វកិច្ច ដើម្បីធានាបាននូវភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី ទាក់ទងនឹងការប្រព្រឹត្តទៅនៃកិច្ចដំណើរការនីតិវិធីនៅចំពោះមុខខ្លួន និងវិស័យរបស់សហចៅក្រមស៊ើបអង្កេត ដែលត្រូវធានាឱ្យបាននូវភាពសម្ងាត់នៃកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣ និង ០០៤ ដើម្បី"ការពារសិទ្ធិ និងផលប្រយោជន៍របស់ភាគី"[49]។ នៅក្នុងរឿងក្តីបច្ចុប្បន្ន បញ្ហានេះ បាននាំទៅដល់ការមិនអនុញ្ញាតឱ្យធ្វើការបង្ហាញនូវឯកសារមួយចំនួន៖ បើទោះបីជា ស.ព.អ ទំនងជាបានកំណត់អត្តសញ្ញាណចម្លើយសាក្សីពាក់ព័ន្ធចំនួន ៣២៨ នៅក្នុងសំណើរបស់ខ្លួននៅខែ ឧសភា និង ខែ តុលា ឆ្នាំ ២០១៤ ថាអាចដាក់បង្ហាញបានក៏ដោយ[50] ក៏ ស.ច.ស.អ កន្លងមកបានអនុញ្ញាតឱ្យបង្ហាញចម្លើយសាក្សីត្រឹមតែចំនួន ១៥២ ប៉ុណ្ណោះ ក្នុងចំណោមចម្លើយសាក្សីទាំងនោះ។ ស្រដៀងនេះគ្នាដែរ ទោះបីនាពេលបច្ចុប្បន្ននេះ ស.ព.អ បានកំណត់អត្តសញ្ញាណឯកសារចំនួន ១៦ ដែលស្ថិតក្នុងប្រភេទនៃភស្តុតាងដោះបន្ទុកដែលមានសក្តានុពលដូចបានបញ្ជាក់នៅក្នុងសំណើនេះក៏ដោយ[51] ក៏ដីកាសម្រេចស្តីពីការដាក់បង្ហាញលើកទី ៣ និងលើកទី ៤ ពុំបានអនុញ្ញាតឱ្យមានការបង្ហាញនូវឯកសារទាំងស្រុងឡើយ ដោយសារឯកសារចំនួនពីរ ពុំទាន់មានសម្រាប់ការប្រើប្រាស់ក្នុងសំណុំរឿង ០០២/០១[52]។

---

[49] វិធាន ៥៦(១) នៃវិធានផ្ទៃក្នុង។ *សូមមើលផងដែរ* សេចក្តីណែនាំអនុវត្តស្តីពីការចាត់ថ្នាក់ឯកសារ និងការរៀបចំព័ត៌មានពាក់ព័ន្ធរឿងក្តី អវតក/០០៤/២០០៩/វិ.២ ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤ មាត្រា ៥, ៨។

[50] ព័ត៌មានដែលអង្គជំនុំជម្រះតុលាការកំពូលបានទទួល មិនអាចឱ្យអង្គជំនុំជម្រះអាចសម្រេចថាតើចម្លើយសាក្សីចំនួន ២០ ដែលបានដាក់បង្ហាញដោយ សំណើរបស់ ស.ព.អ ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៥ និង ចម្លើយសាក្សីចំនួន ៩០ ដែលបានដាក់បង្ហាញដោយសំណើរបស់ ស.ព.អ ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៥ ត្រូវបានបញ្ចូលនៅក្នុងសំណើដើមចំនួនពីររបស់គាត់នៅថ្ងៃទី ១ និង ទី ៥ ខែ ឧសភា ឆ្នាំ ២០១៤ ឬយ៉ាងណាទេ។ ហេតុនេះ ការគណនាខាងលើបន្ថែមរួមគ្នាត្រឹមតែកំណត់ស្តាប់ចម្លើយសាក្សីដែលមានបញ្ចូលក្នុងសំណើចំនួនពីរនៅខែ ឧសភា ឆ្នាំ ២០១៤ និងសំណើមួយនៅខែ តុលា ឆ្នាំ ២០១៤ ប៉ុណ្ណោះ ហើយមិនមែនចម្លើយសាក្សីចំនួន ១១០ ដែលបានដាក់បង្ហាញចុងក្រោយទេ ដោយសារចម្លើយសាក្សីទាំងនោះអាចនឹងត្រូវបានរកឃើញដោយ ស.ព.អ នៅដំណាក់កាលបន្ទាប់ទៀត។

[51] ដីកាសម្រេចដាក់បង្ហាញលើកទី ៣ កថាខណ្ឌ ៤(ង)។

[52] ឧបសម្ព័ន្ធ កៈ ឯកសារដែលបានអនុញ្ញាតឱ្យដាក់បង្ហាញ ឯកសារ E319/12.2 (ភ្ជាប់មកជាមួយនឹង ដីកាសម្រេចដាក់បង្ហាញលើកទី៣) ផ្នែកដែលមានចំណងជើងថា "ឯកសារដែលបានស្នើសុំក្នុងឧបសម្ព័ន្ធ ៥")។ ឧបសម្ព័ន្ធ ខៈ ឯកសារដែលបានអនុញ្ញាតឱ្យដាក់

២២. អង្គជំនុំជម្រះតុលាការកំពូល ទទួលស្គាល់ភារកិច្ចរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការធានាបាននូវភាពសម្ងាត់នៃកិច្ចស៊ើបសួររបស់ខ្លួន។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ សហចៅក្រមស៊ើបអង្កេត ត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួន ក្នុងការវាយតម្លៃលើបញ្ហា ថាតើការជំនុំជម្រះក្តីមួយ អាចធ្វើឡើងប្រកបដោយយុត្តិធម៌ ដែរ ឬយ៉ាងណា បើទោះជាមានការរឹតត្បឹតទៅលើការដាក់បង្ហាញភស្តុតាងក៏ដោយ[53]។ ការអនុវត្តដែលចាំបាច់គឺថា អង្គជំនុំជម្រះ ត្រូវចូលពិនិត្យមើលភស្តុតាងដែល ស.ច.ស.អ មិនទាន់បានអនុញ្ញាតឲ្យដាក់បង្ហាញ ដើម្បីវាយតម្លៃ ថាតើ ការជំនុំជម្រះក្តី នៅតែអាចប្រកបទៅដោយយុត្តិធម៌ ដែរ ឬយ៉ាងណា ក្នុងករណីដែលពុំមានការដាក់បង្ហាញភស្តុតាងទាំងនោះទៅដល់ នួន ជា។ ទាក់ទងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូល អាចត្រូវបានស្នើសុំឲ្យ"សម្រេច ប្រសិនបើមាន លើបញ្ហាថាតើ វិធានការរក្សាតុល្យភាពបែបណាដែលអាចយកមកប្រើប្រាស់បាន ដើម្បីធានាថា សិទ្ធិរបស់ជនជាប់ចោទត្រូវបានការពារ ហើយថា ការជំនុំជម្រះក្តី ត្រូវធ្វើឡើងប្រកបដោយយុត្តិធម៌ ទោះបីពុំមានការអនុញ្ញាតឱ្យធ្វើការបង្ហាញព័ត៌មាននោះក៏ដោយ"[54]។

២៣. លើកលែងតែ ការបង្ហាញនូវឯកសារពីរដែលបានកំណត់ថាស្ថិតក្នុងប្រភេទនៃភស្តុតាងដោះបន្ទុកដែលមានសក្តានុពល ដូចមាននៅក្នុងសំណើនេះ ត្រូវបានធ្វើឡើង នៅពេលចេញសេចក្តីសម្រេចនេះ ទើបសហព្រះរាជអាជ្ញា ត្រូវបានបង្គាប់ឲ្យស្នើសុំការអនុញ្ញាតពីសហចៅក្រមស៊ើបអង្កេត ដើម្បីដាក់បង្ហាញដោយសំអាងលើមូលដ្ឋាននៃភាពសម្ងាត់បំផុត នូវឯកសារទាំងពីរដែលបានពោលខាងលើនេះ តែនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលប៉ុណ្ណោះ។ ប្រសិនបើមានស្ថានភាពស្រដៀងគ្នានេះ កើតឡើងនាពេលអនាគត ដែលក្នុងនោះ សំណើរបស់សហព្រះរាជអាជ្ញា សុំធ្វើការបង្ហាញសម្ភារៈដោយអនុលោមតាមវិធាន ៥៣ (៥) នៃវិធានផ្ទៃក្នុង ពុំត្រូវបានអនុញ្ញាតដោយសហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា ត្រូវបានបង្គាប់ឲ្យអនុវត្តតាមនីតិវិធីដូចគ្នាដែលបានកំណត់នៅក្នុងសេចក្តីសម្រេចនេះ។

---

បង្ហាញ (ពីឯកសារ D193/7) ឯកសារ E319/13.1.3 (ភ្ជាប់មកជាមួយនឹង ដីកាសម្រេចដាក់បង្ហាញលើកទី៥) ផ្នែកដែលមានចំណងជើងថា "ឧបសម្ព័ន្ធ ៥"។ តួលេខដែលបានចង្អុលបង្ហាញមិនបានបញ្ចូលសំណើសុំការកែតម្រូវទេ។

[53] *សូមមើល* តុលាការព្រហ្មទណ្ឌអន្តរជាតិ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង* *Lubanga* សំណុំរឿងលេខ ICC-01/04-01/06-1486 (OA 13) "សាលដីកាលើបណ្តឹងសាទុក្ខរបស់រដ្ឋអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង I មានចំណងជើងថា "សេចក្តីសម្រេចលើផលវិបាកនៃការមិនដាក់បង្ហាញសម្ភារៈដោះបន្ទុកតាមកិច្ចព្រមព្រៀងនៃមាត្រា ៥៤(៣)(ង) និងការអនុវត្តការផ្អាកការចោទប្រកាន់លើជនជាប់ចោទ រួមគ្នាជាមួយបញ្ហាមួយចំនួនផ្សេងទៀតដែលបានលើកឡើងនៅឯសន្និសីទស្តីពីឋានៈ នៅថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១០"" អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៨ ("សេចក្តីសម្រេចស្តីពីការមិនដាក់បង្ហាញក្នុងរឿងក្តី Lubanga") កថាខណ្ឌ ៤៥ ដល់ ៤៧ (ភាសាអង់គ្លេស) (ដោយបានដកស្រង់យុត្តិសាស្ត្រពាក់ព័ន្ធរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប)។

[54] សេចក្តីសម្រេចស្តីពីការមិនដាក់បង្ហាញក្នុងរឿងក្តី Lubanga កថាខណ្ឌ ៤៨ (ភាសាអង់គ្លេស)។

## ឃ.ផ្នែកសម្រេចសេចក្តី

២៤. យោងតាមសំអាងខាងលើ **អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា:-**

**ទទួលយក**ផ្នែកខ្លះនៃសំណើនេះ,

**បង្គាប់មក**សហព្រះរាជអាជ្ញា ឲ្យធ្វើការពិនិត្យមើលលើសំណុំរឿង ០០៣ និង សំណុំរឿង ០០៤ ដើម្បីកំណត់អត្តសញ្ញាណភស្តុតាងដែល៖ (១) ត្រូវបានផ្តល់ឲ្យដោយសាក្សីដែលធ្វើការផ្ទាល់ជាមួយ រស់ ញឹម នៅអំឡុងពេលណាមួយក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឬ (២) ពាក់ព័ន្ធនឹងការប្រឆាំងរបស់ភូមិភាគពាយ័ព្យជាមួយ ប៉ុល ពត និង នួន ជា មុនថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ និងធ្វើការស្នើសុំការអនុញ្ញាតពីសហចៅក្រមស៊ើបអង្កេត ដើម្បីធ្វើការបង្ហាញភស្តុតាងនេះដល់អង្គជំនុំជម្រះតុលាការកំពូល និងភាគី ក្នុងសំណុំរឿង ០០២/០១,

**បង្គាប់មក**សហព្រះរាជអាជ្ញាឲ្យស្នើសុំការអនុញ្ញាតពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដើម្បីធ្វើការបង្ហាញដល់អង្គជំនុំជម្រះតុលាការកំពូលតែមួយគត់ នូវឯកសារចំនួនពីរដែលបានកំណត់អត្តសញ្ញាណ ក្នុងកថាខណ្ឌ ២១ ខាងលើ,

**បង្គាប់**ថា នៅពេលឯកសារនានាដែលមានការជាប់ពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ ពុំត្រូវបានអនុញ្ញាត្តឱ្យធ្វើការបង្ហាញពីសហចៅក្រមស៊ើបអង្កេត បើទោះជាមានសំណើ ពីសហព្រះរាជអាជ្ញាសុំការអនុញ្ញាតធ្វើការបង្ហាញភស្តុតាងតាមវិធាន ៥៣ (៤) នៃវិធានផ្ទៃក្នុង ក៏ដោយ ដូចនេះ សហព្រះរាជអាជ្ញា ត្រូវសុំការអនុញ្ញាតពីសហចៅក្រមស៊ើបអង្កេត ដើម្បីធ្វើការបង្ហាញនូវឯកសារនោះមកអង្គជំនុំជម្រះតុលាការកំពូលតែមួយគត់ ដោយផ្អែកតាមមូលដ្ឋានសម្ងាត់បំផុត។

**រក្សាទុកការទទួលយកមកពិនិត្យ**លើផ្នែកផ្សេងទៀតនៃសំណើនេះ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៥

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រីម**